**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**
លេខ : ០២៤/១៩ ក.ប/ស.ជ.ណ.ម.ព

# សេចក្តីជូនដំណឹង
## ស្តីពី
## ការធ្វើតេស្តជំនាញ និងភាសាជប៉ុនលើកទី១ សម្រាប់ពលករជំនាញផ្នែកថែទាំមនុស្សចាស់ ដើម្បីទៅធ្វើការនៅប្រទេសជប៉ុន

យោងតាមការជូនដំណឹងពីក្រសួងយុត្តិធម៌នៃប្រទេសជប៉ុន ចុះថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១៩ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មានកិត្តិយសសូមជូនដំណឹងដល់ទីភ្នាក់ងារជ្រើសរើសឯកជនទាំងអស់ និងសាធារណជនដែលមានបំណងទៅធ្វើការនៅប្រទេសជប៉ុន ក្នុងគម្រោងពលករជំនាញ ឱ្យបានជ្រាបថា អង្គភាពទទួលបន្ទុកការធ្វើតេស្តជំនាញ និងតេស្តភាសាជប៉ុន នឹងរៀបចំការធ្វើតេស្តជំនាញ និងភាសាជប៉ុន សម្រាប់ផ្នែកថែទាំមនុស្សចាស់ (Nursing Care) លើកទី១ ដែលមានព័ត៌មានលម្អិតដូចខាងក្រោម៖

១. កាលបរិច្ឆេទនៃការសុំចុះឈ្មោះ និងទទួលពាក្យធ្វើតេស្ត៖
- នៅវិទ្យាស្ថានអភិវឌ្ឍវិស័យអប់រំ ៖ ចាប់ពីថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៩ (ចន្ទ ពុធ សុក្រ) ឬ
- តាមប្រព័ន្ធអនឡាញ ៖ ចាប់ពីថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៩
- ឈប់ទទួលពាក្យ និងចុះឈ្មោះ ៖ ត្រឹមថ្ងៃទី៣ ខែកញ្ញា ឆ្នាំ២០១៩

២. កាលបរិច្ឆេទធ្វើតេស្ត ៖ ថ្ងៃទី៧ និងទី៨ ខែកញ្ញា ឆ្នាំ២០១៩

៣. មណ្ឌលធ្វើតេស្ត ៖ វិទ្យាស្ថានអភិវឌ្ឍវិស័យអប់រំ (EDI) អាសយដ្ឋាននៅផ្ទះលេខ២២ ផ្លូវលេខ៥១/១៥៨ សង្កាត់ផ្សារថ្មី៣ ខណ្ឌដូនពេញ រាជធានីភ្នំពេញ។

៤. ការធ្វើតេស្តជំនាញ និងភាសាជប៉ុន

ក. វិញ្ញាសារធ្វើតេស្តជំនាញ និងភាសាជប៉ុនចែកជា ២ផ្នែក៖

ក.១. តេស្តជំនាញថែទាំ មានរយៈពេល ៦០នាទី និងមាន ៤៥សំណួរ

- ការប្រឡងវិញ្ញាសាសរសេរមាន ៤០សំណួរ
  - មូលដ្ឋានគ្រឹះនៃការថែទាំ មាន ១០សំណួរ
  - ការយល់ដឹងផ្នែកអារម្មណ៍ និងរូបរាងកាយ មាន ៦សំណួរ
  - ជំនាញទំនាក់ទំនង មាន ៤សំណួរ
  - ការថែទាំផ្នែករាងកាយ មាន ២០សំណួរ
- ការប្រឡងអនុវត្តមាន ៥សំណួរ

ក.២. តេស្តភាសាជប៉ុនសម្រាប់ជំនាញថែទាំ មានរយៈពេល ៣០នាទី និងមាន ១៥សំណួរ

- ពាក្យបច្ចេកទេសនៃការថែទាំ មាន ៥សំណួរ
- ការសន្ទនាសម្រាប់ផ្នែកថែទាំ មាន ៥សំណួរ
- ការអានអត្ថបទទាក់ទងការថែទាំ មាន ៥សំណួរ

ខ. ពិន្ទុជាប់ គឺចាប់ពី៦០% នៃពិន្ទុសរុបសម្រាប់តេស្តនីមួយៗ

គ. ការធ្វើតេស្តជំនាញ និងភាសាជប៉ុនត្រូវធ្វើឡើងតាមរយៈប្រព័ន្ធកុំព្យូទ័រ (CBT Method)

ឃ. លទ្ធផល នឹងត្រូវជូនដំណឹងមួយខែក្រោយនៃការប្រឡង។

៥. ការបង់ថ្លៃសម្រាប់ទទួលបានសិទ្ធិធ្វើតេស្តជំនាញ និងភាសាជប៉ុន៖

- ៩ដុល្លារ (ប្រាំបួនដុល្លារអាមេរិក) សម្រាប់តេស្តចំណេះដឹងជំនាញថែទាំមនុស្សចាស់
- ៩ដុល្លារ (ប្រាំបួនដុល្លារអាមេរិក) សម្រាប់តេស្តភាសាជប៉ុនជំនាញថែទាំមនុស្សចាស់

៦. លក្ខណៈសម្បត្តិ៖ ត្រូវមានអាយុចាប់ពី ១៧ឆ្នាំ ឡើងទៅ ដោយមិនគិតពីកម្រិតវប្បធម៌

៧. ឯកសារដែលត្រូវភ្ជាប់មកជាមួយ ៖ អត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែន ឬប័ណ្ណបើកបរ។

**កំណត់សម្គាល់៖**

- ❖ ព័ត៌មានអំពីការសុំចុះឈ្មោះ និងទទួលពាក្យធ្វើតេស្តជំនាញ និងភាសាជប៉ុន សូមចូលមើលគេហទំព័រ http://ac.prometric-jp.com/testlist/nc/en/index.html
- ❖ សម្រាប់ព័ត៌មានលម្អិត សូមទំនាក់ទំនងលេខទូរស័ព្ទ +603 76283371(ប្រទេសជប៉ុន) ឬនៅវិទ្យាស្ថានអភិវឌ្ឍវិស័យអប់រំ(EDI) រៀងរាល់ម៉ោងធ្វើការ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមទីភ្នាក់ងារជ្រើសរើសឯកជនទាំងអស់ និងសាធារណជនដែលមានបំណងចង់សុំចុះឈ្មោះ និងទទួលពាក្យធ្វើតេស្តជំនាញ និងភាសាជប៉ុន ជ្រាបតាមការគួរ។

ថ្ងៃ សុក្រ ៨ រោច ខែ ស្រាពណ៍ ឆ្នាំកុរ ឯកស័ក ព.ស២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែ សីហា ឆ្នាំ២០១៩

រដ្ឋមន្ត្រី

អ៊ិត សំហេង

**ចម្លងជូន**

- ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- ក្រសួងមហាផ្ទៃ
- គ្រប់មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត
- សមាគមទីភ្នាក់ងារជ្រើសរើសពលករកម្ពុជា(ACRA)
- សមាគមទីភ្នាក់ងារហត្ថពលកម្មកម្ពុជា(MAC)
- ទីភ្នាក់ងារជ្រើសរើសឯកជនទាំងអស់ "ដើម្បីជួយផ្សព្វផ្សាយ និងសហការ"
- ឯកសារ-កាលប្បវត្តិ